ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២១ លេខ៦១ ត្រីមាសទី០៣ ឆ្នាំ២០២១

# រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា សារាចរ ប្រកាស

ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ

២៦-១០-២០២១ -ព្រះរាជក្រឹត្យ នស/រកត/១០២១/៧៥៧ ស្ដីពី ការផ្ដល់គោរមងារអ្នកស្រី **ទ្រាំ តៃគន់** ជាឧកញ៉ា ៧៤៦១

២៦-១០-២០២១ -ព្រះរាជក្រឹត្យ នស/រកត/១០២១/៧៥៨ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់អ្នកស្រី **លីង តាន់** (LING DAN) ជនជាតិចិន សញ្ជាតិចិន ៧៤៦២

២៦-១០-២០២១ -ព្រះរាជក្រឹត្យ នស/រកត/១០២១/៧៥៩ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **យ៉ុន ដុងសូ** (YOON DONG SOO) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ ដោយប្ដូរឈ្មោះជា **មុន្ថា ឃុន** (MONTHA KUN) ៧៤៦៣

២៧-១០-២០២១ -ព្រះរាជក្រឹត្យ នស/រកត/១០២១/៧៦០ ស្ដីពី ការតែងតាំង និងផ្ដល់ឋានៈជាជំនួយការសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ៣ រូប ៧៤៦៤

២៧-១០-២០២១ -ព្រះរាជក្រឹត្យ នស/រកត/១០២១/៧៦១ ស្ដីពី ការតែងតាំង និងផ្ដល់ឋានៈឯកឧត្ដម **រ័ត្ន សេរី** ជាជំនួយការសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ៧៤៦៥

៣០-១០-២០២១ -ព្រះរាជក្រឹត្យ នស/រកត/១០២១/៧៦២ ស្ដីពី ការតម្លើងឋានន្តរស័ក្ដិ នាយទាហាន ថ្នាក់ឧត្ដមសេនីយ៍ និងថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ មុនចូលនិវត្តន៍ ៦៨ រូប ៧៤៦៦

## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ

១៩-១០-២០២១ -អនុក្រឹត្យលេខ ២០២ អនក្រ.បក ស្ដីពី ការតម្លើងវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញឱ្យមានឋានៈស្មើអគ្គនាយកដ្ឋាន ៧៤៧០

១៩-១០-២០២១ -អនុក្រឹត្យលេខ ២០៣ អនក្រ.បក ស្ដីពី ការតម្លើងវិទ្យាស្ថានគរុកោសល្យបាត់ដំបងឱ្យមានឋានៈស្មើអគ្គនាយកដ្ឋាន ៧៤៧៧

២២-១០-២០២១ -អនុក្រឹត្យលេខ ២០៤ អនក្រ.បក ស្ដីពី ការផ្ទេរឥណទានថវិកា ៧៤៨៤

២៣-៩-២០២១ -ព្រះរាជប្រកាសនីយបត្រលេខ ១៧ ប្រក ស្ដីពី ការតែងតាំងព្រះគ្រូសុវណ្ណគន្ធសីលាចារ្យ **ឈឿន រិទ្ធី** នាមបញ្ញត្តិ ឥន្ទសរោ គង់នៅវត្តសុវណ្ណបុប្ផារាម ឃុំតាពូង ស្រុកថ្មគោល ខេត្តបាត់ដំបង ៧៤៨៦

២៣-៩-២០២១ -ព្រះរាជប្រកាសនីយបត្រលេខ ១៨ ប្រក ស្តីពី ការតែងតាំងព្រះគ្រូធម្មវង្សានមុនី **ផុន សាវេត** នាមបញ្ញត្តិ សង្វេគធម្មោ គង់នៅវត្តព្រះធម្មសំវឌ្ឍនារាម ឃុំវត្តតាមិម ស្រុកសង្កែ ខេត្តបាត់ដំបង ៧៤៨៧

២៣-៩-២០២១ -ព្រះរាជប្រកាសនីយបត្រលេខ ១៩ ប្រក ស្តីពី ការតែងតាំងព្រះគ្រូបត់ត្រសេករតន៍មុនី **ព្រំ វណ្ណធន** នាមបញ្ញត្តិ កុសលធម្មោ គង់នៅវត្តបត់ត្រសេករតនារាម ឃុំព្រៃថ្នង ស្រុកទឹកឈូ ខេត្តកំពត ៧៤៨៨

២៣-៩-២០២១ -ព្រះរាជប្រកាសនីយបត្រលេខ ២០ ប្រក ស្តីពី ការតែងតាំងព្រះគ្រូចន្ទនាមេត្តាធម៌ **ម៉ុល សុវ៉ាត** នាមបញ្ញត្តិ ឱវាទធម្មោ គង់នៅវត្តចន្ទនារាម ឃុំបន្ទាយមាសខាងលិច ស្រុកបន្ទាយមាស ខេត្តកំពត ៧៤៨៩

២៣-៩-២០២១ -ព្រះរាជប្រកាសនីយបត្រលេខ ២១ ប្រក ស្តីពី ការតែងតាំងព្រះគ្រូពោធិមហាមុនី **តុប គីឡា** នាមបញ្ញត្តិ កីឡាបហានោ គង់នៅវត្តសាមគ្គីមានជ័យ ឃុំបឹងសាលាខាងត្បូង ស្រុកកំពង់ត្រាច ខេត្តកំពត ៧៤៩០


## ២~សេចក្តីសម្រេច


២-១១-២០២១ -សេចក្តីសម្រេចលេខ ១០៧ សសរ ស្តីពី ការបំពេញបន្ថែមសមាជិក សមាជិកាក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តព្រះសីហនុ ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា ៧៤៩១

២-១១-២០២១ -សេចក្តីសម្រេចលេខ ១០៨ សសរ ស្តីពី ការបំពេញបន្ថែមសមាជិកក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពត ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា ៧៤៩៣


## III~ការងារបណ្តាក្រសួង

## ១~ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


១៣-១-២០២១ -ប្រកាសលេខ ០១២ សហវ.ប្រក ស្តីពី ការបង្កើតរជ្ជទេយ្យចំណូលសម្រាប់ឆ្នាំ២០២១ នៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ៧៤៩៥

២១-១-២០២១ -ប្រកាសលេខ ០២៧ សហវ.ប្រក ស្តីពី ការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិជូនប្រធានអង្គភាពថវិកា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៧៤៩៩

២៩-១-២០២១ -ប្រកាសលេខ ១០៦ សហវ.ប្រក ស្តីពី ការតែងតាំងរជ្ជទេយ្យករបុរេប្រទាននៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តកោះកុង ៧៥០២

៨-២-២០២១ -ប្រកាសលេខ ១១៧ សហវ.ប្រក ស្តីពី ការតែងតាំងភ្នាក់ងារបើកផ្តល់ និងភ្នាក់ងារបើកផ្តល់ជំនួសនៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តកោះកុង ៧៥០៥

១-៣-២០២១ -ប្រកាសលេខ ១៣៩ សហវ.ប្រក ស្តីពី ការកែសម្រួលនិងតែងតាំងក្រុមលទ្ធកម្មរបស់អគ្គនាយកដ្ឋានរតនាគារជាតិ ៧៥០៨

៥-៣-២០២១ -ប្រកាសលេខ ១៥៨ សហវ.ប្រក ស្តីពី ការបង្កើតគណៈកម្មាធិការប្រយុទ្ធប្រឆាំងជំងឺអេដស៍ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៧៥១០

១៥-៣-២០២១ -ប្រកាសលេខ ១៦៧ សហវ.ប្រក ស្តីពី ការកែសម្រួលនិងតែងតាំងក្រុមលទ្ធកម្មរបស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តស្ទឹងត្រែង ៧៥១៣

១៥-៣-២០២១ -ប្រកាសលេខ ១៦៨ សហវ.ប្រក ស្តីពី ការបង្កើតរជ្ជទេយ្យចំណូលសម្រាប់ឆ្នាំ២០២១ នៅអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ៧៥១៦

**២~ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

១៦-៣-២០២១ -ប្រកាសលេខ ១០៧ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ី.ភី. ខេមបូឌា ចំកាត់បង្កើតរោងចក្រផលិតចំណីសត្វ ៧៥១៩

១៦-៣-២០២១ -ប្រកាសលេខ ១០៨ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន រិតស៍ (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៧៥២២

១៦-៣-២០២១ -ប្រកាសលេខ ១០៩ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ីន យុនហ្វេង (ខេមបូឌា) ហ្វេសិន ឯ.ក បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៧៥២៥

១៦-៣-២០២១ -ប្រកាសលេខ ១១០ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ីអេស ហ្គោលវ ថេកស្តាយ (ខេមបូឌា) ខូ អិលធីឌី បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៧៥២៨

១៦-៣-២០២១ -ប្រកាសលេខ ១១១ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អិល ស៊ី ហ្គាម៉ិន (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ផលិតម៉ាស់ និងថង់យួរដាក់វត្ថុអនុស្សាវរីយ៍គ្រប់ប្រភេទ ៧៥៣១

១៦-៣-២០២១ -ប្រកាសលេខ ១១២ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ប្លេស ហ៊្វុល ហ្វេសិន (ខេមបូឌា) បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ដេរកាបូប និងផលិត Masks, Seat Cover for Car, All kinds of Suitcase ៧៥៣៤

១៨-៣-២០២១ -ប្រកាសលេខ ១១៣ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អេប្រាធី ហ៊្វូដ(ខេមបូឌា) បង្កើតរោងចក្រ ផលិតស្ករគ្រាប់គ្រប់ប្រភេទ ផលិត និងកែច្នៃម្ហូបអាហារ ៧៥៣៧

១៨-៣-២០២១ -ប្រកាសលេខ ១១៤ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ៉ារនេង ខេមកែកឃីជីង ឯ.ក បង្កើតរោងចក្រ ផលិតការ ស្បោងការពារកកិត បង់ស្អិត និងកេសកាតុង ៧៥៤០

១៨-៣-២០២១ -ប្រកាសលេខ ១១៥ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន វ៉ាយ អេច អេស (ខេមបូឌា) ហ៊្វូដ & បេវើរេច បង្កើតរោងចក្រ ផលិតភេសជ្ជៈ ៧៥៤៣

១៨-៣-២០២១ -ប្រកាសលេខ ១១៦ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ខេហ្វខូ អ៉ិនធើណេសិន-ណាល (ខេមបូឌា) លីមីធីត បង្កើតរោងចក្រ ផលិតវត្ថុអនុស្សាវរីយ៍ និងសម្ភារៈគ្រឿងតុបតែងផ្ទះ ៧៥៤៦

## ៣~ទីស្តីការរដ្ឋមន្ត្រីក្រសួងរ៉ែ និង ថាមពល


| | | |
|---|---|---|
| ១៣-១០-២០២០ | -ប្រកាសលេខ ០៤២៧ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៤២៧ រថ.អប្រក.លអ ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០២០ | ៧៥៤៩ |
| ១៣-១០-២០២០ | -ប្រកាសលេខ ០៤២៩ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៤២៩ រថ.អប្រក.លអ ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០២០ | ៧៥៥៣ |
| ១៤-១០-២០២០ | -ប្រកាសលេខ ០៤៣០ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៤៣០ រថ.អប្រក.លអ ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០២០ | ៧៥៥៧ |
| ១៤-១០-២០២០ | -ប្រកាសលេខ ០៤៣៣ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៤៣៣ រថ.អប្រក.លអ ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០២០ | ៧៥៦១ |
| ១៤-១០-២០២០ | -ប្រកាសលេខ ០៤៣៤ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៤៣៤ រថ.អប្រក.លអ ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០២០ | ៧៥៦៥ |
| ១៤-១០-២០២០ | -ប្រកាសលេខ ០៤៣៥ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈលេខ ០៤៣៥ រថ.អប្រក.លអ ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០២០ | ៧៥៦៩ |
| ១៤-១០-២០២០ | -ប្រកាសលេខ ០៤៣៦ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៤៣៦ រថ.អប្រក.លអ ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០២០ | ៧៥៧៣ |
| ១៤-១០-២០២០ | -ប្រកាសលេខ ០៤៣៧ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៤៣៧ រថ.អប្រក.លអ ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០២០ | ៧៥៧៧ |
| ១៤-១០-២០២០ | -ប្រកាសលេខ ០៤៤១ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈលេខ ០៤៤១ រថ.អប្រក.លអ ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០២០ | ៧៥៨១ |
| ១៤-១០-២០២០ | -ប្រកាសលេខ ០៤៤២ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៤៤២ រថ.អប្រក.លអ ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០២០ | ៧៥៨៥ |
| ១៤-១០-២០២០ | -ប្រកាសលេខ ០៤៤៣ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៤៤៣ រថ.អប្រក.លអ ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០២០ | ៧៥៨៩ |
| ១៤-១០-២០២០ | -ប្រកាសលេខ ០៤៤៤ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៤៤៤ រថ.អប្រក.លអ ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០២០ | ៧៥៩៣ |
| ១៤-១០-២០២០ | -ប្រកាសលេខ ០៤៤៥ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៤៤៥ រថ.អប្រក.លអ ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០២០ | ៧៥៩៧ |

# ព្រះរាជក្រឹត្យ

នស/រកត/១០២១/៧៥៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា)

**ត្រាស់បង្គាប់**

ផ្តល់គោរមងារៈ

អ្នកស្រី **ព្រំ តៃគន់**

ជា

**ឧកញ៉ា**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០២១*

**នរោត្តម សីហមុនី**

បានយកសេចក្តីគោរពថ្វាយព្រះមហាក្សត្រ
(ក្នុងករណីចាំបាច់) — 

បានបង្ហាញគ្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

**យើង**

នស/រកត/១០២១/ ១៧៥៨

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់អ្នកស្រី **លីង ដាន់** (LING DAN) ជនជាតិ ចិន សញ្ជាតិ ចិន កើតនៅថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៨២ នៅខេត្តជាំងស៊ី សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

[illegible]

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០២១*

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានបម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/១០២១/ ៧៥៨

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **យ៉ុន ដុងសូ** (YOON DONG SOO) ជនជាតិ កូរ៉េ សញ្ជាតិ កូរ៉េ កើតនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៧០ នៅខេត្តជាងជី សាធារណរដ្ឋកូរ៉េ ដោយប្តូរឈ្មោះជា **មុន្ថា ឃុន** ( MONTHA KUN )។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

៣៥ល. ២១១០. ៧៧៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០២១

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/១០២១/៧៦០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១**: តែងតាំង និងផ្តល់ឋានៈជាជំនួយការសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ០៣រូប៖

១- ឯកឧត្តម **ប្រាជ្ញ សុគន្ធគ្រា** មានឋានៈស្មើ រដ្ឋលេខាធិការ
២- លោកជំទាវ **ឈរ ស្រីពីន** មានឋានៈស្មើ រដ្ឋលេខាធិការ
៣- ឯកឧត្តម **ស៊ើ ឧត្តម** មានឋានៈស្មើ អនុរដ្ឋលេខាធិការ

**មាត្រា២**: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

[illegible]

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០២១*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/១០២១/៧៦១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១**: តែងតាំង និងផ្តល់ឋានៈឯកឧត្តម **រត្ន័ សេរី** ជាជំនួយការសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន។

**មាត្រា២**: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០២១*

**នរោត្តម សីហមុនី**

បានបម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/១០២១/៧៦២

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានតូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តម្លើងឋានន្តរស័ក្តិ នាយទាហាន ថ្នាក់ឧត្តមសេនីយ៍ និងថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ មុនចូលនិវត្តន៍ ៦៨ រូប ៖

**ក-ឋានន្តរស័ក្តិឧត្តមសេនីយ៍ឯក**

១-ឧត្តមសេនីយ៍ទោ **ជា** **ធាសនា** អត្តលេខ ០០៣២១០

២-ឧត្តមសេនីយ៍ទោ **រស់** **សុផាត** អត្តលេខ ០០១៣៨៨

៣-ឧត្តមសេនីយ៍ទោ **សាំង** **អូន** អត្តលេខ ០០១៦២៤

៤-ឧត្តមសេនីយ៍ទោ **ព្រំ** **ឌីក** អត្តលេខ ០០១៦៤១

៥-ឧត្តមសេនីយ៍ទោ **ម៉ា** **សាឌួន** អត្តលេខ ០០០៣១៩

៦-ឧត្តមសេនីយ៍ទោ **អ៊ូ** **សារ៉ុម** អត្តលេខ ០០០៣៣២

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៧-ឧត្តមសេនីយ៍ទោ ហ៊ុំ ចយ អត្តលេខ ០០០៣៥៤
៨-ឧត្តមសេនីយ៍ទោ ខាត់ ធីន អត្តលេខ ០០០២១៣
៩-ឧត្តមសេនីយ៍ទោ គង់ សារី អត្តលេខ ០០០៥៣៩
១០-ឧត្តមសេនីយ៍ទោ ជ័យ ខេង អត្តលេខ ០០០៥៦៦
១១-ឧត្តមសេនីយ៍ទោ មាស ឈឿន អត្តលេខ ០០០៥៨៦
១២ ឧត្តមសេនីយ៍ទោ ស៊ឹម សុភាព អត្តលេខ ០០០៦០៥
១៣-ឧត្តមសេនីយ៍ទោ ឃួន ឡិច អត្តលេខ ០០០៧៣៤
១៤-ឧត្តមសេនីយ៍ទោ តា សិទ្ធ អត្តលេខ ០០១៦២៣

**ខ-ឋានន្តរស័ក្តិឧត្តមសេនីយ៍ទោ**

១-ឧត្តមសេនីយ៍ត្រី សឹង សុខុម អត្តលេខ ០០១៤៧៨
២-ឧត្តមសេនីយ៍ត្រី ជា ទិសុធា អត្តលេខ ០០៨៦៨៦
៣-ឧត្តមសេនីយ៍ត្រី ដួង ស៊ីណា អត្តលេខ ០០០៥៥៣
៤-ឧត្តមសេនីយ៍ត្រី ឡាំ ឆេងមន្ត អត្តលេខ ០០០៦៧០
៥-ឧត្តមសេនីយ៍ត្រី ពុទ្ធិ សំអាឡី អត្តលេខ ០០០៧០៧
៦-ឧត្តមសេនីយ៍ត្រី អ៊ូ សំអុល អត្តលេខ ០០០៥៧៣
៧-ឧត្តមសេនីយ៍ត្រី អ៊ឹម សុផុន អត្តលេខ ០០០៥៧៦
៨-ឧត្តមសេនីយ៍ត្រី មាស ដែន អត្តលេខ ០០០២៤៩
៩-ឧត្តមសេនីយ៍ត្រី ភង សុឃួន អត្តលេខ ០០០៥២៨
១០-ឧត្តមសេនីយ៍ត្រី កែម តារា អត្តលេខ ០០១៧៤២
១១-ឧត្តមសេនីយ៍ត្រី ស៊ិន ឆេន អត្តលេខ ០០៣០៤៥
១២-ឧត្តមសេនីយ៍ត្រី ឯក សំអាន អត្តលេខ ០០៣១៤៧
១៣-ឧត្តមសេនីយ៍ត្រី ថោង វាសនា អត្តលេខ ០០១៤២៤
១៤-ឧត្តមសេនីយ៍ត្រី សៅ សឿន អត្តលេខ ០០១៥៨២
១៥-ឧត្តមសេនីយ៍ត្រី សេក ម៉ានី អត្តលេខ ០០១៥៨៥
១៦-ឧត្តមសេនីយ៍ត្រី ជា សាទី អត្តលេខ ០០៤១២១
១៧-ឧត្តមសេនីយ៍ត្រី ចន ណារិទ្ធសម្បត្តិ អត្តលេខ ០០១៣៨៤
១៨-ឧត្តមសេនីយ៍ត្រី ឌុល សារឿន អត្តលេខ ០០៤៣២៤
១៩-ឧត្តមសេនីយ៍ត្រី សាំង គង់ អត្តលេខ ០០៤៣២៥
២០-ឧត្តមសេនីយ៍ត្រី នរោត្តម ធីរ៉ាវ៉ូ អត្តលេខ ០០៤៣៧៧
២១-ឧត្តមសេនីយ៍ត្រី ពោជ ខេម អត្តលេខ ០១៣៦៩៧
២២-ឧត្តមសេនីយ៍ត្រី ស៊ិន ម៉ិនថន អត្តលេខ ០១៦៧៦៩

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

២៣-ឧត្តមសេនីយ៍ត្រី **នង មណី** អត្តលេខ ០០១៩៦៣
២៤-ឧត្តមសេនីយ៍ត្រី **ឌួន សុផាត** អត្តលេខ ០១៣៨៤៨
២៥-ឧត្តមសេនីយ៍ត្រី **ពិន ពៅ** អត្តលេខ ០១៣៨៩៩
២៦-ឧត្តមសេនីយ៍ត្រី **មាស សាម៉ាត** អត្តលេខ ០០៩៦១៧
២៧-ឧត្តមសេនីយ៍ត្រី **ជុំ សារ៉ាត់** អត្តលេខ ០០១៧៨៣
២៨-ឧត្តមសេនីយ៍ត្រី **ជ័យ សារុន** អត្តលេខ ០១៦០៧៩

**គ-ឋានន្តរស័ក្តិឧត្តមសេនីយ៍ត្រី**

១-វរសេនីយ៍ឯក **រ័ត្ន ផល្លា** អត្តលេខ ០១៤០៤០
២-វរសេនីយ៍ឯក **ស៊ីន ពោធិផល** អត្តលេខ ០១៤០៤៦
៣-វរសេនីយ៍ឯក **អ៊ិត ហោ** អត្តលេខ ០១៤០៨៣
៤-វរសេនីយ៍ឯក **ម៉ក់ សំអាង** អត្តលេខ ០៣១៥៦៩
៥-វរសេនីយ៍ឯក **ញ៉ឹក ប៊ុនឡី** អត្តលេខ ០០០២៣១
៦-វរសេនីយ៍ឯក **ឡឿង និញ** អត្តលេខ ០២៣៩៥២
៧-វរសេនីយ៍ឯក **ហ៊ិន សោម** អត្តលេខ ០០៩៥៩៩
៨-វរសេនីយ៍ឯក **ណុប ថេត** អត្តលេខ ០៣៥១០៨
៩-វរសេនីយ៍ឯក **ខាយ សារ៉ាន** អត្តលេខ ០១៤២៥៣
១០-វរសេនីយ៍ឯក **ឈួច ស៊ីថា** អត្តលេខ ០០៩០៦០
១១-វរសេនីយ៍ឯក **កែវ ហៃ** អត្តលេខ ០១៣៨៦៦
១២-វរសេនីយ៍ឯក **សៀប សាវួន** អត្តលេខ ០១៣៨៦៨
១៣-វរសេនីយ៍ឯក **អ៊ុយ យ៉ុង** អត្តលេខ ០១៣៨៧៦
១៤-វរសេនីយ៍ឯក **ឯក តន្ត្រី** អត្តលេខ ០១៣៨៩៥
១៥-វរសេនីយ៍ឯក **សឹង ឡាយ** អត្តលេខ ០១៩៩៧៤
១៦-វរសេនីយ៍ឯក **នូ ឃឿន** អត្តលេខ ០២៤៧០៧
១៧-វរសេនីយ៍ឯក **ទាល់ ឡាមី** អត្តលេខ ០៣១៧៨៩
១៨-វរសេនីយ៍ឯក **តែ យ៉ាត** អត្តលេខ ០៣៩៦៥៩
១៩-វរសេនីយ៍ឯក **អ៊ូ ហារី** អត្តលេខ ១៧៩៨៤៨
២០-វរសេនីយ៍ឯក **នួម សេរី** អត្តលេខ ០០៨៥៤៩
២១-វរសេនីយ៍ឯក **អ៊ុំ សាឡឿន** អត្តលេខ ០០២២៦៥
២២-វរសេនីយ៍ឯក **អ៊ុំ សារ៉ាត់** អត្តលេខ ០១៧៨០៤
២៣-វរសេនីយ៍ឯក **នង សាមី** អត្តលេខ ០០១៦៤៦
២៤-វរសេនីយ៍ឯក **ប៊ុន សំអុល** អត្តលេខ ០១៧៥០៧



២៥-វរសេនីយ៍ឯក **ពេជ្រ សម្បត្តិ** អត្តលេខ ០២៦៧១៣

២៦-វរសេនីយ៍ឯក **សុក សុមេធី** អត្តលេខ ០៣១៥៧២

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

នស/រកត.១០២១-៧៧៧

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០២១*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ២០២ អនក្រ.បក

**អនុក្រឹត្យ**

**ស្ដីពី**

**ការដំឡើងវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញឱ្យមានឋានៈស្មើអគ្គនាយកដ្ឋាន**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្ដីពីការទទួលស្គាល់គុណភាពអប់រំឧត្ដមសិក្សា
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្ដីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្ដីពីក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា

- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ៧៣ អនក្រ.បក ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដំឡើងកម្រិតបណ្តុះបណ្តាលនិងការបញ្ចូលមជ្ឈមណ្ឌលគរុកោសល្យភូមិភាគរាជធានីភ្នំពេញនិងសាលាគរុកោសល្យនិងវិក្រឹតការរាជធានីភ្នំពេញទៅជាវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានដំឡើងវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញដែលជាគ្រឹះស្ថានអប់រំគ្រូបង្រៀនស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា ពីថ្នាក់ស្មើនាយកដ្ឋានឱ្យមានឋានៈស្មើអគ្គនាយកដ្ឋាន។

## ជំពូកទី២
## តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា២ .-**

វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ត្រូវអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រតាមរូបមន្ត ១២+៤និងវិក្រឹតការគ្រូបង្រៀន និងត្រូវបន្តអនុវត្តតួនាទីនិងភារកិច្ចរបស់ខ្លួនដូចមានចែងនៅក្នុងអនុក្រឹត្យលេខ៧៣ អនក្រ.បក ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដំឡើងកម្រិតបណ្តុះបណ្តាលនិងការបញ្ចូលមជ្ឈមណ្ឌលគរុកោសល្យភូមិភាគរាជធានីភ្នំពេញនិងសាលាគរុកោសល្យនិងវិក្រឹតការរាជធានីភ្នំពេញ ទៅជាវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ។

**មាត្រា៣ .-**

វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ អាចបើកកម្មវិធីអប់រំថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ថ្នាក់បណ្ឌិត និងកម្រិតផ្សេងៗទៀតក្នុងករណីចាំបាច់ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៤ .-**

វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ត្រូវដឹកនាំដោយនាយក១(មួយ)រូបដែលមានឋានៈស្មើអគ្គនាយក និងមាននាយករងមួយចំនួនដែលមានឋានៈស្មើអគ្គនាយករងស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៥ .-**

វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញមានរចនាសម្ព័ន្ធដូចខាងក្រោម៖

១- មហាវិទ្យាល័យស្រាវជ្រាវគរុកោសល្យ។

២- មហាវិទ្យាល័យអប់រំវិទ្យាសាស្ត្រ។

៣- មហាវិទ្យាល័យអប់រំវិទ្យាសាស្ត្រសង្គម។

មហាវិទ្យាល័យនីមួយៗដឹកនាំដោយព្រឹទ្ធបុរស១(មួយ)រូបមានឋានៈស្មើប្រធាននាយកដ្ឋាន និងមានព្រឹទ្ធបុរសរងមួយចំនួនមានឋានៈស្មើអនុប្រធាននាយកដ្ឋានស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញអាចស្នើសុំបង្កើតមហាវិទ្យាល័យបន្ថែមទៀតក្នុងករណីចាំបាច់ដោយអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អង្គការលេខរបស់វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៦ .-**

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ដេប៉ាតឺម៉ង់ចំណុះមហាវិទ្យាល័យនៃវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

## ជំពូកទី៣
## តួនាទីនិងភារកិច្ចរបស់មហាវិទ្យាល័យនីមួយៗ

**មាត្រា៧ .-**

មហាវិទ្យាល័យស្រាវជ្រាវគរុកោសល្យមានតួនាទីជាសេនាធិការឱ្យវិទ្យាស្ថានលើការងារគ្រប់គ្រងដឹកនាំដេប៉ាតឺម៉ង់ចំណុះ សម្របសម្រួល អភិវឌ្ឍ បណ្តុះបណ្តាល និងអនុវត្តកម្មវិធីសិក្សាជំនាញនានាចំណុះឱ្យមហាវិទ្យាល័យ។

មហាវិទ្យាល័យស្រាវជ្រាវគរុកោសល្យមានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មហាវិទ្យាល័យ
- រៀបចំផែនការតម្រូវការនិងប្រើបុគ្គលិកអប់រំសម្រាប់ដេប៉ាតឺម៉ង់និងបណ្ណាល័យ
- ដឹកនាំនិងរៀបចំផែនការអភិវឌ្ឍវិជ្ជាជីវៈនិងប្រឹក្សាគរុកោសល្យជាប្រចាំសម្រាប់មន្ត្រីគ្រប់គ្រងនិងគ្រូឧទ្ទេសទាំងអស់ក្នុងដេប៉ាតឺម៉ង់និងបណ្ណាល័យ
- ដឹកនាំនិងរៀបចំផែនការ អនុវត្ត វាយតម្លៃ និងកែលម្អកម្មវិធីសិក្សាជាប្រចាំរបស់ដេប៉ាតឺម៉ង់និងបណ្ណាល័យ
- រៀបចំនិងត្រួតពិនិត្យការអនុវត្តការងាររបស់ដេប៉ាតឺម៉ង់និងបណ្ណាល័យ ដើម្បីធានាសង្គតិភាពនិងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីអប់រំរបស់វិទ្យាស្ថាន
- ពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តការងារនិងលទ្ធផលការងាររបស់ដេប៉ាតឺម៉ង់និងបណ្ណាល័យ
- សហការជាមួយមហាវិទ្យាល័យពាក់ព័ន្ធក្នុងវិទ្យាស្ថាន ដើម្បីលើកកម្ពស់ការងារស្រាវជ្រាវអប់រំនិងជំរុញនវានុវត្តន៍ក្នុងការអភិវឌ្ឍវិធីសាស្ត្របង្រៀននិងរៀន
- សហការជាមួយដៃគូពាក់ព័ន្ធទាំងក្នុងនិងក្រៅប្រទេស ដើម្បីកៀរគរមូលនិធិនិងកិច្ចគាំទ្រផ្នែកបច្ចេកទេសក្នុងការជំរុញនិងលើកកម្ពស់វប្បធម៌ស្រាវជ្រាវនិងវិធីសាស្ត្ររៀននិងបង្រៀនក្នុងវិទ្យាស្ថាន
- សហការជាមួយការិយាល័យរដ្ឋបាលបុគ្គលិកនិងគណនេយ្យ និងការិយាល័យសិក្សានិងវិក្រឹតការរបស់វិទ្យាស្ថាន

- សហការជាមួយការិយាល័យធានាគុណភាពផ្ទៃក្នុងរបស់វិទ្យាស្ថានក្នុងដំណើរការចុះពិនិត្យតាមដាន និងវាយតម្លៃគុណភាពអប់រំ និងអនុវត្តការងាររបស់មហាវិទ្យាល័យ
- ធ្វើរបាយការណ៍សកម្មភាពតាមកាលកំណត់
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីនាយកវិទ្យាស្ថាន។

**មាត្រា៨ ._**

មហាវិទ្យាល័យអប់រំវិទ្យាសាស្ត្រមានតួនាទីជាសេនាធិការឱ្យវិទ្យាស្ថានលើការងារគ្រប់គ្រង ដឹកនាំដេប៉ាតឺម៉ង់ចំណុះ សម្របសម្រួល អភិវឌ្ឍ បណ្តុះបណ្តាល និងអនុវត្តកម្មវិធីសិក្សាជំនាញនានាចំណុះឱ្យមហាវិទ្យាល័យ។

មហាវិទ្យាល័យអប់រំវិទ្យាសាស្ត្រមានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មហាវិទ្យាល័យអប់រំវិទ្យាសាស្ត្រ
- រៀបចំផែនការតម្រូវការនិងប្រើបុគ្គលិកអប់រំសម្រាប់ដេប៉ាតឺម៉ង់
- ដឹកនាំនិងរៀបចំផែនការ អនុវត្ត វាយតម្លៃ និងកែលម្អកម្មវិធីសិក្សាជាប្រចាំរបស់ដេប៉ាតឺម៉ង់
- ដឹកនាំនិងរៀបចំផែនការអភិវឌ្ឍវិជ្ជាជីវៈនិងប្រឹក្សាគរុកោសល្យជាប្រចាំសម្រាប់មន្ត្រីគ្រប់គ្រង និងគ្រូឧទ្ទេសទាំងអស់ក្នុងដេប៉ាតឺម៉ង់
- រៀបចំនិងត្រួតពិនិត្យការអនុវត្តការងាររបស់ដេប៉ាតឺម៉ង់ ដើម្បីធានាសង្គតិភាពនិងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីអប់រំរបស់វិទ្យាស្ថានគរុកោសល្យ
- ពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តការងារនិងលទ្ធផលការងាររបស់ដេប៉ាតឺម៉ង់
- សហការជាមួយមហាវិទ្យាល័យពាក់ព័ន្ធក្នុងវិទ្យាស្ថាន ដើម្បីលើកកម្ពស់ការងារស្រាវជ្រាវអប់រំ និងជំរុញនវានុវត្តន៍ក្នុងការអភិវឌ្ឍកម្មវិធីសិក្សាក្នុងដេប៉ាតឺម៉ង់
- សហការជាមួយដៃគូពាក់ព័ន្ធទាំងក្នុងនិងក្រៅប្រទេស ដើម្បីកៀរគរមូលនិធិនិងកិច្ចគាំទ្រផ្នែកបច្ចេកទេសក្នុងការជំរុញនិងលើកកម្ពស់វប្បធម៌ស្រាវជ្រាវនិងវិធីសាស្ត្ររៀននិងបង្រៀនក្នុងវិទ្យាស្ថាន
- សហការជាមួយការិយាល័យរដ្ឋបាលបុគ្គលិកនិងគណនេយ្យ និងការិយាល័យសិក្សានិងវិក្រឹតការរបស់វិទ្យាស្ថាន
- សហការជាមួយការិយាល័យធានាគុណភាពផ្ទៃក្នុងរបស់វិទ្យាស្ថានក្នុងដំណើរការចុះពិនិត្យតាមដាន និងវាយតម្លៃគុណភាពអប់រំ និងអនុវត្តការងាររបស់មហាវិទ្យាល័យ
- ធ្វើរបាយការណ៍សកម្មភាពតាមកាលកំណត់
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីនាយកវិទ្យាស្ថាន ។

**មាត្រា៩ ._**

មហាវិទ្យាល័យអប់រំវិទ្យាសាស្ត្រសង្គមមានតួនាទីជាសេនាធិការឱ្យវិទ្យាស្ថានលើការងារគ្រប់គ្រង ដឹកនាំដេប៉ាតឺម៉ង់ចំណុះ សម្របសម្រួល អភិវឌ្ឍ បណ្តុះបណ្តាល និងអនុវត្តកម្មវិធីសិក្សាជំនាញនានាចំណុះឱ្យមហាវិទ្យាល័យ។

មហាវិទ្យាល័យអប់រំវិទ្យាសាស្ត្រសង្គមមានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មហាវិទ្យាល័យ
- រៀបចំផែនការតម្រូវការនិងប្រើបុគ្គលិកអប់រំសម្រាប់ដេប៉ាតឺម៉ង់
- ដឹកនាំនិងរៀបចំផែនការ អនុវត្ត វាយតម្លៃ និងកែលម្អកម្មវិធីសិក្សាជាប្រចាំរបស់ដេប៉ាតឺម៉ង់
- ដឹកនាំនិងរៀបចំផែនការអភិវឌ្ឍវិជ្ជាជីវៈនិងប្រឹក្សាគរុកោសល្យជាប្រចាំសម្រាប់មន្ត្រីគ្រប់គ្រង និងគ្រូឧទ្ទេសទាំងអស់ក្នុងដេប៉ាតឺម៉ង់
- រៀបចំនិងត្រួតពិនិត្យការអនុវត្តការងាររបស់ដេប៉ាតឺម៉ង់ ដើម្បីធានាសង្គតិភាពនិងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីអប់រំរបស់វិទ្យាស្ថាន
- ពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តការងារនិងលទ្ធផលការងាររបស់ដេប៉ាតឺម៉ង់
- សហការជាមួយមហាវិទ្យាល័យពាក់ព័ន្ធក្នុងវិទ្យាស្ថានដើម្បីគាំទ្របច្ចេកទេសដល់ដេប៉ាតឺម៉ង់
- សហការជាមួយដៃគូពាក់ព័ន្ធក្នុងនិងក្រៅប្រទេស ដើម្បីគាំទ្រផ្នែកបច្ចេកទេសក្នុងការអនុវត្តកម្មវិធីសិក្សារបស់ដេប៉ាតឺម៉ង់ ដើម្បីធានាបាននូវប្រសិទ្ធភាពនិងគុណភាពនៃការអប់រំគ្រូបង្រៀនក្នុងវិទ្យាស្ថាន
- សហការជាមួយការិយាល័យរដ្ឋបាលបុគ្គលិកនិងគណនេយ្យ និងការិយាល័យសិក្សានិងវិក្រឹតការរបស់វិទ្យាស្ថាន
- សហការជាមួយការិយាល័យធានាគុណភាពផ្ទៃក្នុងរបស់វិទ្យាស្ថានក្នុងដំណើរការចុះពិនិត្យតាមដាននិងវាយតម្លៃគុណភាពអប់រំ និងអនុវត្តការងាររបស់មហាវិទ្យាល័យ
- ធ្វើរបាយការណ៍សកម្មភាពតាមកាលកំណត់
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីនាយកវិទ្យាស្ថាន។

## ជំពូកទី៤
## បទប្បញ្ញត្តិដោយឡែក

**មាត្រា១០ .-**

គរុនិស្សិតដែលបានបំពេញគ្រប់លក្ខខណ្ឌនៃកម្មវិធីអប់រំតាមរូបមន្ត១២+៤ដោយជោគជ័យ ត្រូវទទួលបានសញ្ញាបត្របរិញ្ញាបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀនតាមកម្មវិធីអប់រំនិងឯកទេសដែលបានសិក្សា។ សញ្ញាបត្រនេះត្រូវចេញដោយវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ទៅតាមបញ្ជីឈ្មោះគរុនិស្សិតដែលបានបញ្ចប់ការសិក្សាជាស្ថាពរ ដែលមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា១១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១៣កើត ខែ អស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ២០២១ ✓

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ២០២ អនក្រ.បក ថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០២១
ស្តីពីការការដំឡើងវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញឱ្យមានឋានៈស្មើអគ្គនាយកដ្ឋាន

**អង្គការលេខរបស់វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ (វ.គ.ភ.)**



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២០៣ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការដំឡើងវិទ្យាស្ថានគរុកោសល្យបាត់ដំបងឱ្យមានឋានៈស្មើអគ្គនាយកដ្ឋាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា

- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដំឡើងកម្រិតបណ្តុះបណ្តាលនិងការបញ្ចូលមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តបាត់ដំបងនិងសាលាគរុកោសល្យនិងវិក្រឹតការខេត្តបាត់ដំបងទៅជាវិទ្យាស្ថានគរុកោសល្យបាត់ដំបង
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានដំឡើងវិទ្យាស្ថានគរុកោសល្យបាត់ដំបងដែលជាគ្រឹះស្ថានអប់រំគ្រូបង្រៀនស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា ពីថ្នាក់ស្មើនាយកដ្ឋានឱ្យមានឋានៈស្មើអគ្គនាយកដ្ឋាន។

## ជំពូកទី២

## តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា២ .-**

វិទ្យាស្ថានគរុកោសល្យបាត់ដំបង ត្រូវអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញបត្រតាមរូបមន្ត១២+៤ និងវិក្រឹតការគ្រូបង្រៀន និងត្រូវបន្តអនុវត្តតួនាទីនិងភារកិច្ចរបស់ខ្លួនដូចមានចែងនៅក្នុងអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដំឡើងកម្រិតបណ្តុះបណ្តាលនិងការបញ្ចូលមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តបាត់ដំបង និងសាលាគរុកោសល្យនិងវិក្រឹតការខេត្តបាត់ដំបង ទៅជាវិទ្យាស្ថានគរុកោសល្យបាត់ដំបង។

**មាត្រា៣ .-**

វិទ្យាស្ថានគរុកោសល្យបាត់ដំបង អាចបើកកម្មវិធីអប់រំថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ថ្នាក់បណ្ឌិត និងកម្រិតផ្សេងៗទៀតក្នុងករណីចាំបាច់ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៤ .-**

វិទ្យាស្ថានគរុកោសល្យបាត់ដំបង ត្រូវដឹកនាំដោយនាយក១(មួយ)រូបដែលមានឋានៈស្មើអគ្គនាយក និងមាននាយករងមួយចំនួនដែលមានឋានៈស្មើអគ្គនាយករងស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៥ .-**

វិទ្យាស្ថានគរុកោសល្យបាត់ដំបងមានរចនាសម្ព័ន្ធដូចខាងក្រោម៖

១- មហាវិទ្យាល័យស្រាវជ្រាវគរុកោសល្យ។

២- មហាវិទ្យាល័យអប់រំវិទ្យាសាស្ត្រ។

៣- មហាវិទ្យាល័យអប់រំវិទ្យាសាស្ត្រសង្គម។

មហាវិទ្យាល័យនីមួយៗដឹកនាំដោយព្រឹទ្ធបុរស១(មួយ)រូបមានឋានៈស្មើប្រធាននាយកដ្ឋាន និងមានព្រឹទ្ធបុរសរងមួយចំនួនមានឋានៈស្មើអនុប្រធាននាយកដ្ឋានស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

វិទ្យាស្ថានគរុកោសល្យបាត់ដំបងអាចស្នើសុំបង្កើតមហាវិទ្យាល័យបន្ថែមទៀតក្នុងករណីចាំបាច់ ដោយអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អង្គការលេខរបស់វិទ្យាស្ថានគរុកោសល្យបាត់ដំបង ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៦ .-**

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ដេប៉ាតឺម៉ង់ចំណុះមហាវិទ្យាល័យនៃវិទ្យាស្ថានគរុកោសល្យបាត់ដំបង ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

## ជំពូកទី៣
## តួនាទីនិងភារកិច្ចរបស់មហាវិទ្យាល័យនីមួយៗ

**មាត្រា៧ .-**

មហាវិទ្យាល័យស្រាវជ្រាវគរុកោសល្យមានតួនាទីជាសេនាធិការឱ្យវិទ្យាស្ថានលើការងារគ្រប់គ្រង ដឹកនាំដេប៉ាតឺម៉ង់ចំណុះ សម្របសម្រួល អភិវឌ្ឍ បណ្តុះបណ្តាល និងអនុវត្តកម្មវិធីសិក្សាជំនាញនានាចំណុះឱ្យមហាវិទ្យាល័យ។

មហាវិទ្យាល័យស្រាវជ្រាវគរុកោសល្យមានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មហាវិទ្យាល័យ
- រៀបចំផែនការតម្រូវការនិងប្រើបុគ្គលិកអប់រំសម្រាប់ដេប៉ាតឺម៉ង់និងបណ្ណាល័យ
- ដឹកនាំនិងរៀបចំផែនការអភិវឌ្ឍវិជ្ជាជីវៈនិងប្រឹក្សាគរុកោសល្យជាប្រចាំសម្រាប់មន្ត្រីគ្រប់គ្រង និងគ្រូឧទ្ទេសទាំងអស់ក្នុងដេប៉ាតឺម៉ង់និងបណ្ណាល័យ
- ដឹកនាំនិងរៀបចំផែនការ អនុវត្ត វាយតម្លៃ និងកែលម្អកម្មវិធីសិក្សាជាប្រចាំរបស់ដេប៉ាតឺម៉ង់និងបណ្ណាល័យ
- រៀបចំនិងត្រួតពិនិត្យការអនុវត្តការងាររបស់ដេប៉ាតឺម៉ង់និងបណ្ណាល័យ ដើម្បីធានាសង្គតិភាព និងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីអប់រំរបស់វិទ្យាស្ថាន
- ពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តការងារនិងលទ្ធផលការងាររបស់ដេប៉ាតឺម៉ង់និងបណ្ណាល័យ
- សហការជាមួយមហាវិទ្យាល័យពាក់ព័ន្ធក្នុងវិទ្យាស្ថាន ដើម្បីលើកកម្ពស់ការងារស្រាវជ្រាវអប់រំ និងជំរុញនវានុវត្តន៍ក្នុងការអភិវឌ្ឍវិធីសាស្ត្របង្រៀននិងរៀន
- សហការជាមួយដៃគូពាក់ព័ន្ធទាំងក្នុងនិងក្រៅប្រទេស ដើម្បីកៀរគរមូលនិធិនិងកិច្ចគាំទ្រផ្នែកបច្ចេកទេសក្នុងការជំរុញនិងលើកកម្ពស់វប្បធម៌ស្រាវជ្រាវនិងវិធីសាស្ត្ររៀននិងបង្រៀនក្នុងវិទ្យាស្ថាន
- សហការជាមួយការិយាល័យរដ្ឋបាលបុគ្គលិកនិងគណនេយ្យ និងការិយាល័យសិក្សានិងវិក្រឹតការរបស់វិទ្យាស្ថាន

- សហការជាមួយការិយាល័យធានាគុណភាពផ្ទៃក្នុងរបស់វិទ្យាស្ថានក្នុងដំណើរការចុះពិនិត្យតាមដាន និងវាយតម្លៃគុណភាពអប់រំ និងអនុវត្តការងាររបស់មហាវិទ្យាល័យ
- ធ្វើរបាយការណ៍សកម្មភាពតាមកាលកំណត់
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីនាយកវិទ្យាស្ថាន។

**មាត្រា៨ .-**

មហាវិទ្យាល័យអប់រំវិទ្យាសាស្ត្រមានតួនាទីជាសេនាធិការឱ្យវិទ្យាស្ថានលើការងារគ្រប់គ្រង ដឹកនាំដេប៉ាតឺម៉ង់ចំណុះ សម្របសម្រួល អភិវឌ្ឍ បណ្តុះបណ្តាល និងអនុវត្តកម្មវិធីសិក្សាជំនាញនានាចំណុះឱ្យមហាវិទ្យាល័យ។

មហាវិទ្យាល័យអប់រំវិទ្យាសាស្ត្រមានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មហាវិទ្យាល័យអប់រំវិទ្យាសាស្ត្រ
- រៀបចំផែនការតម្រូវការនិងប្រើបុគ្គលិកអប់រំសម្រាប់ដេប៉ាតឺម៉ង់
- ដឹកនាំនិងរៀបចំផែនការ អនុវត្ត វាយតម្លៃ និងកែលម្អកម្មវិធីសិក្សាជាប្រចាំរបស់ដេប៉ាតឺម៉ង់
- ដឹកនាំនិងរៀបចំផែនការអភិវឌ្ឍវិជ្ជាជីវៈនិងប្រឹក្សាគរុកោសល្យជាប្រចាំសម្រាប់មន្ត្រីគ្រប់គ្រង និងគ្រូឧទ្ទេសទាំងអស់ក្នុងដេប៉ាតឺម៉ង់
- រៀបចំនិងត្រួតពិនិត្យការអនុវត្តការងាររបស់ដេប៉ាតឺម៉ង់ ដើម្បីធានាសង្គតិភាពនិងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីអប់រំរបស់វិទ្យាស្ថានគរុកោសល្យ
- ពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តការងារនិងលទ្ធផលការងាររបស់ដេប៉ាតឺម៉ង់
- សហការជាមួយមហាវិទ្យាល័យពាក់ព័ន្ធក្នុងវិទ្យាស្ថាន ដើម្បីលើកកម្ពស់ការងារស្រាវជ្រាវអប់រំ និងជំរុញនវានុវត្តន៍ក្នុងការអភិវឌ្ឍកម្មវិធីសិក្សាក្នុងដេប៉ាតឺម៉ង់
- សហការជាមួយដៃគូពាក់ព័ន្ធទាំងក្នុងនិងក្រៅប្រទេស ដើម្បីកៀរគរមូលនិធិនិងកិច្ចគាំទ្រផ្នែកបច្ចេកទេសក្នុងការជំរុញនិងលើកកម្ពស់វប្បធម៌ស្រាវជ្រាវនិងវិធីសាស្ត្ររៀននិងបង្រៀនក្នុងវិទ្យាស្ថាន
- សហការជាមួយការិយាល័យរដ្ឋបាលបុគ្គលិកនិងគណនេយ្យ និងការិយាល័យសិក្សានិងវិក្រឹតការរបស់វិទ្យាស្ថាន
- សហការជាមួយការិយាល័យធានាគុណភាពផ្ទៃក្នុងរបស់វិទ្យាស្ថានក្នុងដំណើរការចុះពិនិត្យតាមដាន និងវាយតម្លៃគុណភាពអប់រំ និងអនុវត្តការងាររបស់មហាវិទ្យាល័យ
- ធ្វើរបាយការណ៍សកម្មភាពតាមកាលកំណត់
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីនាយកវិទ្យាស្ថាន ។

**មាត្រា៩ .-**

មហាវិទ្យាល័យអប់រំវិទ្យាសាស្ត្រសង្គមមានតួនាទីជាសេនាធិការឱ្យវិទ្យាស្ថានលើការងារគ្រប់គ្រង ដឹកនាំដេប៉ាតឺម៉ង់ចំណុះ សម្របសម្រួល អភិវឌ្ឍ បណ្តុះបណ្តាល និងអនុវត្តកម្មវិធីសិក្សាជំនាញនានាចំណុះឱ្យមហាវិទ្យាល័យ។

មហាវិទ្យាល័យអប់រំវិទ្យាសាស្ត្រសង្គមមានភារកិច្ចដូចខាងក្រោមៈ

- រៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មហាវិទ្យាល័យ
- រៀបចំផែនការតម្រូវការនិងប្រើបុគ្គលិកអប់រំសម្រាប់ដេប៉ាតឺម៉ង់
- ដឹកនាំនិងរៀបចំផែនការ អនុវត្ត វាយតម្លៃ និងកែលម្អកម្មវិធីសិក្សាជាប្រចាំរបស់ដេប៉ាតឺម៉ង់
- ដឹកនាំនិងរៀបចំផែនការអភិវឌ្ឍវិជ្ជាជីវៈនិងប្រឹក្សាគរុកោសល្យជាប្រចាំសម្រាប់មន្ត្រីគ្រប់គ្រង និងគ្រូឧទ្ទេសទាំងអស់ក្នុងដេប៉ាតឺម៉ង់
- រៀបចំនិងត្រួតពិនិត្យការអនុវត្តការងាររបស់ដេប៉ាតឺម៉ង់ ដើម្បីធានាសង្គតិភាពនិងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីអប់រំរបស់វិទ្យាស្ថាន
- ពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តការងារនិងលទ្ធផលការងាររបស់ដេប៉ាតឺម៉ង់
- សហការជាមួយមហាវិទ្យាល័យពាក់ព័ន្ធក្នុងវិទ្យាស្ថានដើម្បីគាំទ្របច្ចេកទេសដល់ដេប៉ាតឺម៉ង់
- សហការជាមួយដៃគូពាក់ព័ន្ធក្នុងនិងក្រៅប្រទេស ដើម្បីគាំទ្រផ្នែកបច្ចេកទេសក្នុងការអនុវត្តកម្មវិធីសិក្សារបស់ដេប៉ាតឺម៉ង់ ដើម្បីធានាបាននូវប្រសិទ្ធភាពនិងគុណភាពនៃការអប់រំគ្រូបង្រៀនក្នុងវិទ្យាស្ថាន
- សហការជាមួយការិយាល័យរដ្ឋបាលបុគ្គលិកនិងគណនេយ្យ និងការិយាល័យសិក្សានិងវិក្រឹតការរបស់វិទ្យាស្ថាន
- សហការជាមួយការិយាល័យធានាគុណភាពផ្ទៃក្នុងរបស់វិទ្យាស្ថានក្នុងដំណើរការចុះពិនិត្យតាមដាន និងវាយតម្លៃគុណភាពអប់រំ និងអនុវត្តការងាររបស់មហាវិទ្យាល័យ
- ធ្វើរបាយការណ៍សកម្មភាពតាមកាលកំណត់
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីនាយកវិទ្យាស្ថាន។

## ជំពូកទី៤
## បទប្បញ្ញត្តិដោយឡែក

**មាត្រា១០ .-**

គរុនិស្សិតដែលបានបំពេញគ្រប់លក្ខខណ្ឌនៃកម្មវិធីអប់រំតាមរូបមន្ត១២+៤ដោយជោគជ័យ ត្រូវទទួលបានសញ្ញាបត្របរិញ្ញាបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀនតាមកម្មវិធីអប់រំនិងឯកទេសដែលបានសិក្សា។ សញ្ញាបត្រនេះត្រូវចេញដោយវិទ្យាស្ថានគរុកោសល្យបាត់ដំបង ទៅតាមបញ្ជីឈ្មោះគរុនិស្សិតដែលបានបញ្ចប់ការសិក្សាជាស្ថាពរ ដែលមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា១១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១៣កើតខែ អស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ២០៣ អនក្រ.បក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ២០២១
ស្តីពីការការដំឡើងវិទ្យាស្ថានគរុកោសល្យបាត់ដំបងឱ្យមានឋានៈស្មើអគ្គនាយកដ្ឋាន

**អង្គភាពលេខរបស់វិទ្យាស្ថានគរុកោសល្យបាត់ដំបង (វ.គ.ប.)**



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** : ២០៤ អនក្រ.បក

# អនុក្រឹត្យ
# ស្ដីពី
# ការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្ដីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃ ព្រហស្បតិ៍ ០១រោច ខែ បឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២០/០៣៨ ចុះថ្ងៃ សុក្រ ១១កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៧ ស្ដីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២១៧ អនក្រ.បក ចុះថ្ងៃ អង្គារ ១៥កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០២០ ស្ដីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១ .-**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ១ ៥២៤ ៨០០ ០០០ រៀល (មួយប៊ីលានប្រាំរយម្ភៃបួនលានប្រាំបីរយពាន់រៀលគត់) ពីជំពូក ៦៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក ៦១ (សេវាកម្ម) ជូនក្រសួងព្រះបរមរាជវាំង សម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១។

**មាត្រា២ .-**

ការបែងចែកឥណទានថវិកាចំណាយផ្ទេរក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ទូទាត់ជម្រះថវិកាបុរេប្រទានចំណាយក្នុងឱកាស **ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ព្រះអង្គស្តេចយាងពិនិត្យព្រះរាជសុខភាពនៅទីក្រុងប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា៣ .-**

រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១ រោច ខែ អស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជប្រកាសនីយបត្រ

## គណៈសង្ឃពុទ្ធសាសនារដ្ឋ នៃព្រះរាជាណាចក្រកម្ពុជា
## និកាយធម្មយុត្តខ្មែរ

សុភមស្តុពុទ្ធស័ករាជ២៥៦៥ ថ្ងៃចន្ទ ១កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ត្រូវនឹងថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២១

**សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី កិត្តិឧទ្ទេសបណ្ឌិត**

**សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា**

**និងជាព្រះប្រធានគណៈសង្ឃនាយក នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ នស/រកត/១០០៧/៥៣៨ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៧ ស្តីពីការថ្វាយព្រះគោរម្យងារ សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ នស/រកត/០៩១០/៧២៦ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការបង្កើតគណៈសង្ឃនាយក នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់សេចក្តីក្រាបបង្គំទូលថ្វាយលេខ ០៤/២១ សគធ.បប ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២១ របស់ព្រះមេគណ គណៈធម្មយុត្តិកនិកាយខេត្តមណ្ឌលគិរី ចំណារឯកភាពលេខ ៥៤/២១ ធសខ.បប ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២១ របស់មន្ទីរធម្មការ និងសាសនាខេត្តបាត់ដំបង និងសេចក្តីក្រាបបង្គំទូលថ្វាយលេខ ៣៣៧/២១ ណ.ស ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ របស់ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តបាត់ដំបង
- បានទ្រង់យល់សេចក្តីសម្រេចនៃអង្គប្រជុំគណៈសង្ឃនាយកស្តីពីការតែងតាំង-ដកហូតមន្ត្រីសង្ឃ ព្រះចៅអធិការ និងគណៈកម្មការ អាចារ្យ នៃវត្តគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់សម្រេច**

តែងតាំងព្រះគ្រូសុវណ្ណគន្ធសីលាចារ្យ **ឈឿន រិទ្ធី** នាមបញ្ញត្តិ **ឥន្ទសរោ** គង់នៅ **វត្តសុវណ្ណបុប្ផារាម** ឃុំតាពូង ស្រុកថ្មគោល ខេត្តបាត់ដំបង អាយុ ៣៥ ឆ្នាំ កើតថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៨៦ ក្នុងភូមិអូរបេក ឃុំត្រពាំងជង ស្រុកបាកាន ខេត្តពោធិ៍សាត់ ងារដើម **ព្រះចៅអធិការ** ឲ្យឡើងជា **ព្រះធម្មធរគណា គណៈធម្មយុត្តិកនិកាយខេត្តបាត់ដំបង** ។

សូមឲ្យបានទទួលនូវសេចក្តីសុខសេចក្តីចម្រើនក្នុងព្រះពុទ្ធសាសនាជាភិយ្យោភាពតរៀងទៅ ។

លេខ.១៧...ព្រ.ក..................

ថ្ងៃច... ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
...០៩ ខែសីហា ឆ្នាំ២០២១
...មហាសង្ឃរាជាធិបតី
...បណ្ឌិត

(ហត្ថលេខា)

ឃុំ-ត្រី

បានឃើញ និងឯកភាព

ថ្ងៃ... ខែ... ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី...ខែ...ឆ្នាំ២០២១
នាយករដ្ឋមន្ត្រី

(ហត្ថលេខា)

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

ឆ្នាំទី២១ លេខ ៦១ រាជកិច្ច ទំព័រ ៧៤៨៦

# ព្រះរាជប្រកាសនីយបត្រ

គណៈសង្ឃពុទ្ធសាសនារដ្ឋ នៃព្រះរាជាណាចក្រកម្ពុជា

និកាយធម្មយុត្តខ្មែរ

សុភមស្តុពុទ្ធស័ករាជ២៥៦៥ ថ្ងៃចន្ទ ១កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ត្រូវនឹងថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២១

សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី កិត្តិឧទ្ទេសបណ្ឌិត

សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

និងជាព្រះប្រធានគណៈសង្ឃនាយក នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ នស/រកត/១០០៧/៥៣៨ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៧ ស្តីពីការថ្វាយព្រះគោរម្យងារ សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ នស/រកត/០៩១០/៧២៦ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការបង្កើតគណៈសង្ឃនាយក នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់សេចក្តីក្រាបបង្គំទូលថ្វាយលេខ ០៤/២១ សគណ.បប ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២១ របស់ព្រះមេគណ គណៈធម្មយុត្តិកនិកាយខេត្តមណ្ឌលគិរី ចំណារឯកភាពលេខ ៥៤/២១ ធស១.បប ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២១ របស់មន្ទីរធម្មការ និងសាសនាខេត្តបាត់ដំបង និងសេចក្តីក្រាបបង្គំទូលថ្វាយលេខ ៣៣៤/២១ ឈ.ស ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ របស់ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តបាត់ដំបង
- បានទ្រង់យល់សេចក្តីសម្រេចនៃអង្គប្រជុំគណៈសង្ឃនាយកស្តីពីការតែងតាំង-ដកហូតមន្ត្រីសង្ឃ ព្រះចៅអធិការ និងគណៈកម្មការ អាចារ្យ នៃវត្តគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

<u>ត្រាស់សម្រេច</u>

តែងតាំងព្រះគ្រូធម្មវន្សឧមុនី **ផុន សារឧត** នាមបញ្ញត្តិ **សរទ្វតធរេម្មា** គង់នៅ **វត្តព្រះធម្មសំឧន្សនារាម** ឃុំវត្តតាមិម ស្រុកសង្កែ ខេត្តបាត់ដំបង អាយុ ៥០ ឆ្នាំ កើតថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៧១ ក្នុងភូមិចោយយ៉ង់ សង្កាត់តាម៉ឺន ក្រុងបាត់ដំបង ខេត្តបាត់ដំបង ងារដើម **ព្រះបាឡាត់គណខេត្ត** ឲ្យទទួលតួនាទីបន្ថែមជា **ព្រះអនុគណ គណៈធម្មយុត្តិកនិកាយក្រុងបាត់ដំបង** ។

សូមឲ្យបានទទួលនូវសេចក្តីសុខសេចក្តីចម្រើនក្នុងព្រះពុទ្ធសាសនាជាភិយ្យោភាពរៀងទៅ ។

លេខ ១៤ ប្រក

ថ្ងៃចន្ទ ១កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ត្រូវនឹងថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២១

សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី

កិត្តិឧទ្ទេសបណ្ឌិត

បានឃើញ និងឯកភាព

ថ្ងៃព្រហស្បតិ៍ ២កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី.....ខែ.....ឆ្នាំ២០២១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

# ព្រះរាជប្រកាសនីយបត្រ

## គណៈសង្ឃពុទ្ធសាសនារដ្ឋ នៃព្រះរាជាណាចក្រកម្ពុជា
## និកាយធម្មយុត្តខ្មែរ

សុភមស្តុពុទ្ធស័ករាជ២៥៦៥ ថ្ងៃចន្ទ ១កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ត្រូវនឹងថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២១
សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី កិត្តិឧទ្ទេសបណ្ឌិត
សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា
និងជាព្រះប្រធានគណៈសង្ឃនាយក នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ នស/រកត/១០០៧/៥៣៨ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៧ ស្តីពីការថ្វាយព្រះគោរម្យងារ សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ នស/រកត/០៩១០/៧២៦ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការបង្កើតគណៈសង្ឃនាយក នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់សេចក្តីក្រាបបង្គំទូលថ្វាយលេខ ០០៧/២១ សគធ-ខកព/លស ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១ របស់ព្រះមេគណ គណៈធម្មយុត្តិកនិកាយខេត្តកំពត ចំណារឯកភាពលេខ ០០៤/២១ លចប ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២១ របស់មន្ទីរធម្មការ និងសាសនាខេត្តកំពត និងសេចក្តីក្រាបបង្គំទូលថ្វាយលេខ ០៣៦/២១ ល.ស ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១ របស់ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តកំពត
- បានទ្រង់យល់សេចក្តីសម្រេចនៃអង្គប្រជុំគណៈសង្ឃនាយកស្តីពីការតែងតាំង-ដកហូតមន្ត្រីសង្ឃ ព្រះចៅអធិការ និងគណៈកម្មការ- អាចារ្យ នៃវត្តគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់សម្រេច

តែងតាំងព្រះគ្រូបត់ត្រសេករតន៍មុនី ប្រាំ ខណ្ណរតន នាមបញ្ញត្តិ កុសលធម្មោ គង់នៅវត្តបត់ត្រសេករតនារាម ឃុំព្រៃថ្នង ស្រុកទឹកឈូ ខេត្តកំពត អាយុ ៥៧ ឆ្នាំ កើតថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៦៤ ក្នុងភូមិជីឃ្មូល់ ឃុំគោកព្រិច ស្រុកគិរីវង់ ខេត្តតាកែវ ងារដើម ព្រះចៅអធិការ ឱ្យឡើងជា ព្រះអនុគណ គណៈធម្មយុត្តិកនិកាយស្រុកទឹកឈូ ។

សូមឱ្យបានទទួលនូវសេចក្តីសុខសេចក្តីចម្រើនក្នុងព្រះពុទ្ធសាសនាជាភិយ្យោភាពតរៀងទៅ ។

លេខ...១៥ ព្រក.................

បានឃើញ និងឯកភាព

ថ្ងៃព្រហស្បតិ៍ ៣កើត ខែ ភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី៧៣.. ខែ..កញ្ញា...ឆ្នាំ២០២១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ថ្ងៃចន្ទ ១កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ត្រូវនឹងថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២១

សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី

កិត្តិឧទ្ទេសបណ្ឌិត

បួរ_គ្រី

# ព្រះរាជប្រកាសនីយបត្រ

## គណៈសង្ឃពុទ្ធសាសនារដ្ឋ នៃព្រះរាជាណាចក្រកម្ពុជា
## និកាយធម្មយុត្តខ្មែរ

សុភមស្តុពុទ្ធស័ករាជ២៥៦៥ ថ្ងៃចន្ទ ១កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ត្រូវនឹងថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២១

**សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី កិត្តិឧទ្ទេសបណ្ឌិត**
**សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា**
**និងជាព្រះប្រធានគណៈសង្ឃនាយក នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ នស/រកត/១០០៧/៥៣៨ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៧ ស្តីពីការថ្វាយព្រះគោរម្យងារ សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ នស/រកត/០៩១០/៧២៦ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការបង្កើតគណៈសង្ឃនាយក នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់សេចក្តីក្រាបបង្គំទូលថ្វាយលេខ ០០៧/២១ សគធ-ខកព/លស ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១ របស់ព្រះមេគណ គណៈធម្មយុត្តិកនិកាយខេត្តកំពត ចំណារឯកភាពលេខ ០០៤/២១ លចប ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២១ របស់មន្ទីរធម្មការ និងសាសនាខេត្តកំពត និងសេចក្តីក្រាបបង្គំទូលថ្វាយលេខ ០៣៦/២១ ល.ស ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១ របស់ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តកំពត
- បានទ្រង់យល់សេចក្តីសម្រេចនៃអង្គប្រជុំគណៈសង្ឃនាយកស្តីពីការតែងតាំង-ដកហូតមន្ត្រីសង្ឃ ព្រះចៅអធិការ និងគណៈកម្មការ អាចារ្យ នៃវត្តគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

### ត្រាស់សម្រេច

តែងតាំងព្រះគ្រូចន្ទនាមេត្តាធម៌ **ម៉ុល សុខ៉ាត** នាមបញ្ញត្តិ **ឱភាសធម្មោ** គង់នៅ **វត្តចន្ទនារាម** ឃុំបន្ទាយមាសខាងលិច ស្រុកបន្ទាយមាស ខេត្តកំពត អាយុ ៣១ ឆ្នាំ កើតថ្ងៃទី០២ ខែសីហា ឆ្នាំ១៩៩៥ ក្នុងភូមិថ្មី ឃុំផុង ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ងារដើម **ព្រះចៅអធិការ** ឲ្យឡើងជា **ព្រះអនុគណ គណៈធម្មយុត្តិកនិកាយស្រុកបន្ទាយមាស** ។

សូមឱ្យបានទទួលនូវសេចក្តីសុខសេចក្តីចម្រើនក្នុងព្រះពុទ្ធសាសនាជាភិយ្យោភាពតរៀងទៅ ។

លេខ........................

ថ្ងៃ... ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
... ខែសីហា ឆ្នាំ២០២១

**សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី**
**...**

បានឃើញ និងឯកភាព

ថ្ងៃ............ខែ............ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី.........ខែ.........ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# ព្រះរាជប្រកាសនីយបត្រ

## គណៈសង្ឃពុទ្ធសាសនារដ្ឋ នៃព្រះរាជាណាចក្រកម្ពុជា
## និកាយធម្មយុត្តិខ្មែរ

សុភមស្តុពុទ្ធស័ករាជ២៥៦៥ ថ្ងៃចន្ទ ១កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ត្រូវនឹងថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២១

**សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី កិត្តិឧទ្ទេសបណ្ឌិត**

**សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា**

**និងជាព្រះប្រធានគណៈសង្ឃនាយក នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ នស/រកត/១០០៧/៥៣៨ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៧ ស្តីពីការថ្វាយព្រះគោរម្យងារ សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ នស/រកត/០៩១០/៧២៦ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការបង្កើតគណៈសង្ឃនាយក នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់សេចក្តីក្រាបបង្គំទូលថ្វាយលេខ ០០៧/២១ សគធ-ខកព/លស ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១ របស់ព្រះមេគណ គណៈធម្មយុត្តិកនិកាយខេត្តកំពត ចំណារឯកភាពលេខ ០០៤/២១ លចប ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២១ របស់មន្ទីរធម្មការ និងសាសនាខេត្តកំពត និងសេចក្តីក្រាបបង្គំទូលថ្វាយលេខ ០៣៦/២១ ល.ស ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១ របស់ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តកំពត
- បានទ្រង់យល់សេចក្តីសម្រេចនៃអង្គប្រជុំគណៈសង្ឃនាយកស្តីពីការតែងតាំង-ដកហូតមន្ត្រីសង្ឃ ព្រះចៅអធិការ និងគណៈកម្មការ អាចារ្យ នៃវត្តគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

### ត្រាស់សម្រេច

តែងតាំងព្រះគ្រូពោធិមហាមុនី **គុប គីឡា** នាមបញ្ញត្តិ **គីឡាបហារោ** គង់នៅ **វត្តសាមគ្គីមានជ័យ** ឃុំបឹងសាលាខាងត្បូង ស្រុកកំពង់ត្រាច ខេត្តកំពត អាយុ ៤១ ឆ្នាំ កើតថ្ងៃទី០២ ខែឧសភា ឆ្នាំ១៩៨៥ ក្នុងភូមិអូរម្កាក់ ឃុំដំបូកខ្ពស់ ស្រុកអង្គរជ័យ ខេត្តកំពត ជារដើម **ព្រះចៅអធិការ** ឲ្យឡើងជា **ព្រះអនុគណ គណៈធម្មយុត្តិកនិកាយស្រុកកំពង់ត្រាច ។**

សូមឲ្យបានទទួលនូវសេចក្តីសុខសេចក្តីចម្រើនក្នុងព្រះពុទ្ធសាសនាជាភិយ្យោភាពតរៀងទៅ ។

លេខ [illegible]

បានឃើញ និងឯកភាព

ថ្ងៃ[illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦[illegible]

រាជធានីភ្នំពេញ, ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

ថ្ងៃ[illegible] ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

[illegible] ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២១

**សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី**

**កិត្តិឧទ្ទេសបណ្ឌិត**

**ប៊ូរ-គ្រី**

ឆ្នាំទី២១ លេខ៦១ រាជកិច្ច ទំព័រ ៧៤៩០

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១០៧ សសរ

# សេចក្ដីសម្រេច

## ស្ដីពី

## ការបំពេញបន្ថែមសមាជិក សមាជិកាក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន ខេត្តព្រះសីហនុ ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៩២ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត
- យោងសេចក្ដីណែនាំលេខ ០១ សណន ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩ ស្ដីពីតួនាទី ភារកិច្ច និងរបៀបរបបការងារសម្រាប់ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានរាជធានី ខេត្ត ក្នុងការបំពេញបេសកកម្ម ដើម្បីត្រួតពិនិត្យ និងគាំទ្រកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល
- យោងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៦ នៃរដ្ឋសភា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## សម្រេច

**ប្រការ១ .-**

ត្រូវបានបំពេញបន្ថែមសមាជិក សមាជិកាក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន**ខេត្តព្រះសីហនុ** ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម **ប្រាក់ ថាវអមិដា** | អគ្គលេខាធិការរងក្រុមប្រឹក្សាជាតិ អភិវឌ្ឍន៍ដោយចីរភាព ក្រសួងបរិស្ថាន | សមាជិក |
| ២. លោក **ស្រី ស៊ិនលាង** | អគ្គនាយករង អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ក្រសួងបរិស្ថាន | សមាជិក |
| ៣. លោកស្រី **ថៃ សិលាទីណា** | អគ្គនាយករង អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ក្រសួងបរិស្ថាន | សមាជិកា |
| ៤. លោក **លឿង កេសរោ** | អគ្គនាយករង អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ក្រសួងបរិស្ថាន | សមាជិក |
| ៥. លោក **រាត់ ស៊ិទ្ធ** | អគ្គនាយករង អគ្គនាយកដ្ឋានគាំពារបរិស្ថាន ក្រសួងបរិស្ថាន | សមាជិក |
| ៦. លោក **ឡេង គឹមស្រ៊ុង** | អគ្គនាយករង អគ្គនាយកដ្ឋានគាំពារបរិស្ថាន ក្រសួងបរិស្ថាន | សមាជិក |

**ប្រការ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋបាលខេត្តព្រះសីហនុ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃ អង្គារ ១២រោច ខែ អស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ២០២១

**ឧប.នាយករដ្ឋមន្ត្រី**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

<u>កន្លែងទទួល:</u>

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ១០៨៤ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបំពេញបន្ថែមសមាជិកក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពត ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៩២ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត
- យោងសេចក្តីណែនាំលេខ ០១ សណន ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩ ស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងារសម្រាប់ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានរាជធានី ខេត្ត ក្នុងការបំពេញបេសកកម្ម ដើម្បីត្រួតពិនិត្យ និងគាំទ្រកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល
- យោងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៦ នៃរដ្ឋសភា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## សម្រេច

**ប្រការ១ .-**

ត្រូវបានបំពេញបន្ថែម ឯកឧត្តម **នេត្រ ភក្ត្រា** រដ្ឋលេខាធិការក្រសួងបរិស្ថាន ជាសមាជិកក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន**ខេត្តកំពត** ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា។

**ប្រការ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋបាលខេត្តកំពត និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១២រោច ខែ អស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២ ខែវិច្ឆិកា ឆ្នាំ២០២១

**តប.នាយករដ្ឋមន្ត្រី**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

*កន្លែងទទួល:*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០១២ ......សហវ.ប្រក

**ប្រកាស**
**ស្តីពី**
**ការបង្កើតរង្វេធេយ្យចំណូលសម្រាប់ឆ្នាំ២០២១**
**នៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤១២ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ន/ស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២០/០៣៨ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនី នៃប្លង់គណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៣៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ស្តីពីការបង្កើតនិងដាក់ឱ្យដំណើរការអង្គភាពថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ១២៨២ សហវ.ប្រក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ស្តីពីសិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិកាកម្មវិធីរបស់អង្គភាពថវិកា
- បានឃើញប្រកាសលេខ ១៨៩០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការគ្រប់គ្រងរជ្ជទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៣៣៦ សហវ.ប្រក ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិលើរជ្ជទេយ្យចំណូល ជូនប្រធានអង្គភាពថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៨៤១ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិ លើឥណទានថវិការជ្ជទេយ្យបុរេប្រទាន ជូនប្រធានអង្គភាពថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៥៦៩ សហវ.ប្រក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិជូនប្រធានអង្គភាពថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១១២៩ សហវ.ប្រក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨ ស្តីពីការកែសម្រួល និងការបង្កើតបន្ថែមគណនី និងអនុគណនីនៃចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកានៃប្រកាសលេខ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៦១៥ សហវ.ប្រកចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការបង្កើតបន្ថែមគណនី និងអនុគណនី នៃប្លង់គណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១០១១ សហវ.ប្រក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២០ ស្តីពីការតែងតាំងរជ្ជទេយ្យករចំណូលរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតរជ្ជទេយ្យចំណូល នៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដើម្បីធ្វើការប្រមូលចំណូលមិនមែនសារពើពន្ធផ្សេងៗ អនុលោមតាមបទប្បញ្ញត្តិជាធរមាន។ បញ្ជីរាយប្រភេទចំណូល ដែលត្រូវបានអនុញ្ញាតឱ្យប្រមូលដោយរជ្ជទេយ្យករចំណូលមានដូចខាងក្រោម÷

| ល.រ | អនុគណនី | បរិយាយ | ចំនួនទឹកប្រាក់ |
|---|---|---|---|
| ១. | ៧៣០១២ | លក់ឯកសារ លតាប័ត្រ និងលិខិតបោះពុម្ពផ្សេងៗ | ២៦.១៥០.០០០.០០០ រៀល |
| ២. | ៧៣០២៤ | ផលពីការបង់សិទ្ធិប្រឡង(កម្រៃសេវាបង់ថ្លៃសិទ្ធិប្រឡង និងសិក្សាវគ្គជើងសារគយ) | ៥០.០០០.០០០ រៀល |
| ៣. | ៧៣០២៨ | ចំណូលពីការអនុញ្ញាតរដ្ឋបាលទម្រង់ការរដ្ឋបាលនិងការគ្រប់គ្រងរដ្ឋបាលផ្សេងៗ÷<br>-កម្រៃចុះបញ្ជិកាប្រតិវេទន៍គយនាំចេញនាំចូល និងឆ្លងកាត់<br>-កម្រៃបែបបទគយ<br>-កម្រៃប័ណ្ណសម្គាល់មធ្យោបាយដឹកជញ្ជូន<br>-កម្រៃសេវាកែតម្រូវ ឬធ្វើទុតិយតាបង្កាន់ដៃពន្ធ និងលតាបត្រ | ៣៣.៤៥០.០០០.០០០រៀល |
| ៤. | ៧៣០៤៨ | ផលពីសេវាផ្សេងៗ÷<br>-កម្រៃផ្តល់សេវាតាមវិធានបញ្ជាក់ជាមុន<br>-កម្រៃការងារក្រៅពីការិយាល័យគយ | ៨៥០.០០០.០០០ រៀល |
| ៥. | ៧៣០៦៦ | ចំណូលពីអាជ្ញាប័ណ្ណក្នុងស្រុក÷<br>-កម្រៃអាជ្ញាប័ណ្ណសន្និធិគយបណ្តោះអាសន្ន<br>-កម្រៃអាជ្ញាប័ណ្ណភណ្ឌាគារគយមានដែនកំណត់<br>-កម្រៃអាជ្ញាប័ណ្ណជើងសាគយ | ៩០០.០០០.០០០ រៀល |
| ៦. | ៧៣០៨៧ | ផលពីការត្រួតពិនិត្យគុណភាពផលិតផល និងការគោរពបទដ្ឋាន (កម្រៃត្រួតពិនិត្យ កុងតឺន័រតាមម៉ាស៊ីនស្កែន) | ១២.៦០០.០០០.០០០ រៀល |
| | | **សរុបទឹកប្រាក់** | **៧៤.០០០.០០០.០០០ រៀល** |

**ប្រការ២.-**

ចំនួនទឹកប្រាក់អតិបរមា ដែលអនុញ្ញាតទុកក្នុងបេឡាមានកំណត់ត្រឹមចំនួន ២.០០០.០០០ រៀល (ពីរលានរៀលគត់)

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ អគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការ នៃអគ្គាធិការដ្ឋាន នាយកវិទ្យាស្ថាន ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិង

៣ Pha 8

ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ [illegible] ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ មករា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ឧត្តមបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាមីអង្គភាពថវិកា
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ០២៧ ...... សហវ.ប្រក

# ប្រកាស
# ស្តីពី
# ការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិ ជូនប្រធានអង្គភាពថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤១២ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ន/ស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២០/០៣៨ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤២៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងដាក់ឱ្យអនុវត្តអង្គភាពថវិកា
- បានឃើញប្រកាសលេខ ៨៥៦ សហវ.ប្រក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីការរៀបចំ និងចាប់ផ្តើមអនុវត្តអង្គភាពថវិកា
- បានឃើញប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ១២៨២ សហវ.ប្រក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ស្តីពីសិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិកាកម្មវិធីរបស់អង្គភាពថវិកា
- បានឃើញប្រកាសលេខ ១៨៤១ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិ លើឥណទានថវិការដ្ឋទេយ្យបុរេប្រទាន ជូនប្រធានអង្គភាពថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៣៧៣ សហវ.ប្រក ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទរបស់អគ្គនាយកដ្ឋានទ្រព្យសម្បត្តិ និងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៣៣៥ សហវ.ប្រក ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិលើឥណទានថវិកាចំណាយបន្ទុកបុគ្គលិក ជូនប្រធានអង្គភាពថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.–**

ត្រូវបានប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិ សម្រាប់កិច្ចប្រតិបត្តិការហិរញ្ញវត្ថុលើឥណទានថវិកាប្រចាំឆ្នាំ ចាប់ពីឆ្នាំ ២០២១ តទៅ ជូនអគ្គនាយក នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ២.–**

ឥណទានថវិការបស់អង្គភាពថវិកានីមួយៗ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ចំណាយក្នុងឆ្នាំសារពើពន្ធត្រូវបានកំណត់នៅក្នុងប្រកាសស្តីពីការបែងចែកឥណទានចំណាយថវិកាកម្មវិធីថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំសារពើពន្ធ។

ឥណទាននេះត្រូវបែងចែកតាមមាតិកាកម្មវិធី (អនុកម្មវិធី និងចង្កោមសកម្មភាព) និងមាតិកាសេដ្ឋកិច្ច (ក្រុម ប្រភេទ ជំពូក គណនី និងអនុគណនី) ដែលត្រូវបានកំណត់ក្នុងសៀវភៅថវិកាកម្មវិធីឆ្នាំសារពើពន្ធសម្រាប់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៣.–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែមករា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- សាមីអង្គភាពថវិកា
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១០៥ សហវ.ប្រក

ប្រកាស

ស្តីពី

ការតែងតាំងជំនួយការប្រធាន

នៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខេត្តកោះកុង

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមិនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៩ និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៩/១១ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៥១នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

- បានឃើញអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែ តុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកានៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ៦៦៣ សហវ.ប្រក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសលេខ១៣៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ស្តីពីការបង្កើតនិងដាក់ឱ្យដំណើរការអង្គភាពថវិកា របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញសេចក្តីណែនាំលេខ០០៥ សហវ.ប្រក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីគោលការណ៍និងនីតិវិធីផ្ទៃក្នុងសម្រាប់អនុវត្តថវិកាកម្មវិធី របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកោះកុង

## សម្រេច

**ប្រការ១ ._**

ត្រូវបានតែងតាំងមន្ត្រីរាជការ នៃមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខេត្តកោះកុង ដូចខាងក្រោម ÷

១-កញ្ញា **រស់ ចរិយា** មុខងារ អនុប្រធានការិយាល័យបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ ជារជ្ជទេយ្យករបុរេទាន នៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកោះកុង

២-លោក **សេខ សុជាតិ** មុខងារ ប្រធានការិយាល័យបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ ជារជ្ជទេយ្យករបុរេប្រទានរង នៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខេត្តកោះកុង។

៣-កញ្ញា **ស៊ុម ដាទីន** មុខងារ មន្ត្រីការិយាល័យបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ ជារជ្ជទេយ្យករបុរេប្រទានរង នៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខេត្តកោះកុង



ហ៊

**ប្រការ២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១រោច ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល**

- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងមុខងារសាធារណៈ
- -ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- -ដូចប្រការ៣
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១១៩៧ សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការតែងតាំងភ្នាក់ងារបើកផ្តល់ និងភ្នាក់ងារបើកផ្តល់ជំនួស នៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខេត្តកោះកុង

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤១២ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/ រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ. បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសារធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្ដីពីការអនុវត្តបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្ដីពីការដាក់ឱ្យអនុវត្តមាតិកាគណនី នៃប្លង់គណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៣៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ស្ដីពីការបង្កើតនិងដាក់ឱ្យដំណើរការអង្គភាពថវិកា របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្ដីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្ដីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ១៨៤២ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ ស្ដីពីការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិជូនប្រធានអង្គភាពថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១២៨២ សហវ.ប្រក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ស្ដីពីសិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិកាកម្មវិធីរបស់អង្គភាពថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១១២៩ សហវ.ប្រក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨ ស្ដីពីការកែសម្រួល និងការបង្កើតបន្ថែមគណនី និងអនុគណនីនៃចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកានៃប្រកាសលេខ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៦១៥ សហវ.ប្រកចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨ ស្ដីពីការបង្កើតបន្ថែមគណនី និងអនុគណនី នៃប្លង់គណនេយ្យសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ប្រាក់បៀវត្សរ៍មន្ត្រីរាជការ និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ នៃមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខេត្តកោះកុង ត្រូវបើកផ្ដល់តាមរយៈភ្នាក់ងារបើកផ្ដល់។

**ប្រការ២.-**

ត្រូវបានតែងតាំងភ្នាក់ងារបើកផ្ដល់ និងភ្នាក់ងារបើកផ្ដល់ជំនួស នៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកោះកុង ដូចមានសមាសភាពខាងក្រោម÷

| | | | |
|---|---|---|---|
| ១. លោក | **សេង សុជាតិ** | ប្រធានការិយាល័យបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ | ជាភ្នាក់ងារបើកផ្ដល់ |
| ២. កញ្ញា | **រស់ ចរិយា** | អនុប្រធានការិយាល័យបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ | ជាភ្នាក់ងារបើកផ្ដល់ជំនួស |
| ៣. កញ្ញា | **ស៊ឹម ដាវីន** | មន្ត្រីការិយាល័យបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ | ជាភ្នាក់ងារបើកផ្ដល់ជំនួស |

**ប្រការ៣.-**

លោក **សេង សុជាតិ** ជាភ្នាក់ងារបើកផ្ដល់ កញ្ញា **រស់ ចរិយា** និងកញ្ញា **ស៊ឹម ដាវីន** ជាភ្នាក់ងារបើកផ្ដល់ជំនួសត្រូវបានអនុញ្ញាតឱ្យបើកគណនីប្រាក់បញ្ញើនៅរតនាគារខេត្ត ដើម្បីទទួលមូលនិធិសម្រាប់យកទៅបើកប្រាក់បៀវត្សរ៍ និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ជូនមន្ត្រីរាជការ។

**ប្រការ៤._**

បែបបទនៃការអនុវត្តបើកផ្តល់ប្រាក់បៀវត្សរ៍ និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ ត្រូវបានកំណត់ដោយសេចក្តីណែនាំក្រោយ។

**ប្រការ៥._**

ភ្នាក់ងារបើកផ្តល់ ត្រូវទទួលខុសត្រូវផ្ទាល់ចំពោះប្រាក់កាស និងមូលនិធិដែលបានទទួល ដើម្បីយកទៅធ្វើការបើកផ្តល់ជូនមន្ត្រីរាជការ។

**ប្រការ៦._**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៧._**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូទទួលបន្ទុកជាអគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋាន អគ្គនាយក អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកវិទ្យាស្ថានប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ២ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- សាមីអង្គភាពថវិកា
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៣៣៥ សហវ.ប្រក

# ប្រកាស
# ស្តីពី
# កែសម្រួលនិងតែងតាំងក្រុមលទ្ធកម្ម
# របស់អគ្គនាយកដ្ឋានរតនាគារជាតិ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤១២ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួល សមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីនីតិវិធី នៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសារធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

- បានឃើញប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តលទ្ធកម្មវិធី
- បានឃើញប្រកាសលេខ ១២៨២ សហវ.ប្រក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ស្តីពីសិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តលទ្ធកម្មវិធីរបស់អង្គភាពថវិកា
- បានឃើញប្រកាសលេខ ២៤៩ សហវ. ប្រក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការបង្កើតក្រុមលទ្ធកម្មរបស់អង្គភាពថវិកា
- បានឃើញប្រកាសលេខ ១៣៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ស្តីពីការបង្កើតនិងដាក់ឱ្យដំណើរការអង្គភាពថវិកា របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៨៤១ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិជូនប្រធានអង្គភាពថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## **សម្រេច**

**ប្រការ១.-**

ត្រូវបានកែសម្រួល និងតែងតាំងក្រុមលទ្ធកម្ម របស់អគ្គនាយកដ្ឋានរតនាគារជាតិ មានសមាសភាពដូចតទៅ÷

| | | | |
|---|---|---|---|
| ១.ឯកឧត្តមបណ្ឌិត | **ម៉េង ប៊ុនឆ័ន្ទ្រាវុធ** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ | ជាប្រធាន |
| ២.ឯកឧត្តម | **ហេង សុខណា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរតនាគារជាតិ | ជាអនុប្រធាន |
| ៣.លោក | **ង៉ា សុទី** | ប្រធាននាយកដ្ឋានរដ្ឋបាលនិងបុគ្គលិក | ជាសមាជិក |
| ៤. លោក | **អឿន ច័ន្ទវិសុទ្ធ** | អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងបុគ្គលិក | ជាសមាជិក |
| ៥. លោក | **ពុន ហាខៀន** | ប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ | ជាសមាជិក។ |

**ប្រការ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកវិទ្យាស្ថាន ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៣រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មីនា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី កសហវ.
- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- សាមីអង្គភាពថវិកា
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០៥៥៧ សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការបង្កើតគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍

## ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/១៨ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្ការនិងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានសមាសភាពដូចខាងក្រោម÷

| | | | |
|---|---|---|---|
| ១-លោកជំទាវ | **កែវ ចរិយា** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២-លោកជំទាវ | **រស់ ច័ន្ទស្រស់** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធានប្រចាំការ |



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

៣- លោកជំទាវ **លឹម ឈុនលី** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន

៤-ឯកឧត្តម **ស៊ាង ផល្លា** អនុរដ្ឋលេខាធិការ និងជាប្រធានលេខាធិការដ្ឋាន នៃក្រុមប្រឹក្សានីតិកម្ម អនុប្រធាន

៥-ឯកឧត្តម **មាស សុខសេនសាន** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

៦-ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ សមាជិក

៧-ឯកឧត្តម **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា អគ្គនាយក នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា សមាជិក

៨-ឯកឧត្តម **វង្ស ប៊ុនឥន្ទ្រាវុធ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ សមាជិក

៩-ឯកឧត្តម **ហាវ រតនៈ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា សមាជិក

១០-ឯកឧត្តម **កែវ ចេងវឌ្ឍន៍** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ សមាជិក

